00721802

E107/3

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 08 / 2011
ម៉ោង (Time/Heure): 11 : 06
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសីង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS

00721803



**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីការបស់អង្គបុរេជំនុំជម្រះ ចេញនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ដែលបានសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ។

**បានទទួល** សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលកំណត់ដើម្បីអាចដាក់ការឆ្លើយតបរួមមួយទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី ស្តីពីសហឧក្រិដ្ឋកម្មរួម III, អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ឯកសារ E107/1) ដែលបានដាក់នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១១ ("សំណើទីមួយ") និងសំណើទីពីររបស់សហព្រះរាជអាជ្ញា សុំពន្យារពេលឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីស្តីពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E107/2) ដែលបានដាក់នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ("សំណើទីពីរ")។

**បានឃើញ** វិធាន៣៩(៤)(ក) នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះពន្យារពេលវេលាកំណត់តាមគំនិតផ្តួចផ្តើមរបស់ខ្លួន និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.០៦ ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ដែលចែងថា ពេលវេលាកំណត់ត្រូវរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក។

**បានឃើញ** ផងដែរនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យារពេល ចេញនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារ E107) ដែលអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E95, E96, E99, E100 យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់សារណាតបរបស់ខ្លួន យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១១ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងធ្វើការឆ្លើយតប។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។

**បានឃើញ** នៅចន្លោះពេលនេះ ចម្លើយតបរបស់មេធាវីការពារក្តី និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ជាភាសាអង់គ្លេស និងបារាំង និងត្រូវបានជូនដំណឹងអំពីឯកសារចម្លើយតបទាំងនេះជាភាសាខ្មែរ តាមពេលក្រោយជាបន្តបន្ទាប់។

**បានឃើញ**ផងដែរនូវការឆ្លើយឆ្លងពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ទៅសហព្រះរាជអាជ្ញា នៅថ្ងៃទី ២៦ និង ទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ជាបន្តបន្ទាប់ ដែលបញ្ជាក់ថា អង្គជំនុំជម្រះអាចនឹងផ្តល់ការអនុញ្ញាតតាមសំណើទាំងពីរ។

**យល់ឃើញថា** ការឆ្លើយតបជារួមរបស់សហព្រះរាជអាជ្ញា អាចបង្កើនប្រសិទ្ធិភាព និងកាត់បន្ថយការរាំងស្ទះលើការបកប្រែ និងយល់ឃើញដែរថា មិនមានផលប៉ះពាល់អាចកើតចេញពីការផ្តល់តាមសំណើទាំងនេះ។

**ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេច**

**អនុញ្ញាត** តាមសំណើ និងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ការឆ្លើយតបរួមបញ្ចូលគ្នារបស់ខ្លួន ក្នុងរយៈពេលដប់ (១០) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃចម្លើយតបចុងក្រោយជាភាសាខ្មែរ។

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

និល ណុន